# ការលចៅស្រទបចេកក្លាយជាអ្នកមានបុណ្យ

## (បទពំនោល)

ព្រះឥន្ទ្រពិតពិនពុំលង់ ក្លែងកាយជាអង្គ តាចាស់ព្រឹទ្ធាមួយណា។
ដៃកាន់ឈើច្រត់យុរយារ ស្លាយពរពស្រ្តា លីលាចរចូលរោងរត្នា។
ដើរដល់មណ្ឌលនោះថ្វាត់ អង្គឥន្ទ្រាសត្យ សាសងសំណេះទៅថា។
ហៃចៅកំលោះសោភា ដេកថ្វីច្នេះណា មកទៅនឹងតាឆាប់ឡើង។
ទៅមើលអ្នកមានបុណ្យថ្កើង ឱ្យច្បាស់ខ្លួនយើង កុំចាំខ្ជីភ្នែកគេឡើយ។
ស្រទបចេកស្ដាប់ជាក់ហើយ ទើបងើបឆ្លាសឆ្លើយ តាអើយខ្ញុំទៅពុំបាន។
លោកគ្រូអាចារ្យឱ្យទាន ចាំទីរោងរាន នូវអស់ឥវ៉ាន់គរគោក។
ទៅលេងក្រែងបាត់ផងលោក មនុស្សដើររអោក រហល់រចល់ពុំដាច់។
ឃើញស្វាត់កាត់ចូលរំពេច ឆក់បានវេះគេច មិនឈប់មិនឈរបាត់ទៅ។
ម្ល៉ោះហើយនឹងកើតអាស្រូវ ភាសខ្មាសគេកូវ គេជេរគេវាយពុំខាន។
អញ្ជើញចុះលោកតាក្សាន្ត ខ្ញុំឃើញជាខាន ពុំបានទៅនឹងតាឡើយ។



ឯឥន្ទ្រតាចាស់ស្តាប់ហើយ ថាហៃចៅអើយ បើឈ្មោះអាណិតតាម្តង។
ឱ្យផ្ញើបង្វេចមួយផង ពោធីឆ្លើយឆ្លង ថាបង្វេចតាមានអ្វី។
ឯអង្គឥន្ទ្រាធិបតី ប្រាប់ទៅវិញខ្ចី ថាអាវសំពត់ទេតើ។
ពោធិសត្វឆ្លើយថាបើ តាផ្ញើក៏ផ្ញើ ខ្ញុំនឹងសល់ក្រផ្ញើអ្វី។
តែខ្ញុំថប់ក្រែងពេកក្រៃ ជួនជាមានភ័យ យកមួយចោលមួយណាទៅ។
តាចាស់ផ្លាសឆ្លើយចៅរៅ ថាបើអ្នកចៅ ខ្លាចបាត់ខ្លាចបង់ផងតា។
ចូរចៅស្ទៀកពាក់ទៅណា ខ្ជាប់នឹងអាត្មា ឱ្យអស់កុំឱ្យសល់នៅ។
ផ្តាំស្រេចតាចាស់ចេញទៅ ចាកទីលំនៅ នៃពិធពង្សពោធិសត្វ។
ថ្លែងពីដំរីបុស្សរថ តម្រង់មកថ្វាត់ ចំរោងពោធីអ្នកនៅ។
មនុស្សម្នាត្រៀបត្រាខ្នួលខ្មៅ ដើរហែរតាមទៅ ប្រកិតជិតជើងគជសារ។



រីឯពោធីសត្វា យង់យល់មនុស្សម្នា អឺងកងតម្រង់ទីឋាន។
ភិតភ័យក្រៃពន់ប្រមាណ ទើបប្រវាបាន បង្ហិចតាចាស់នោះណា។
គន់គិតក្នុងចិត្តថៃថា ឥឡូវទ្រព្យតា គាត់ផ្ញើនឹងអញជៀងជាក់។
ផ្តាំថាបើមានផ្អើលភ្ញាក់ ឱ្យអញស្ទៀកពាក់ កុំឱ្យតែបាត់ផងគាត់។

ពុំលង់ចមពង្សពុទ្ធរត្ន ស្រាយបង្វេចថ្វាត់ ចាប់យកសំពត់ពស្ត្រា។
មកស្លៀកពាក់ស្រេចសព្វសា សល់នៅមកុដណា គិតថាជាម្ជួកមួយសោះ។
ហើយខ្លាចបាត់ម្ជួកតានោះ ទើបអង្គកំលោះ លើកមកុដពេជ្រមកពាក់ផ្គង។
សមអង្គសមទ្រង់កន្លង ហាក់ឥន្ទ្រហោះផ្សង ចុះចាកពីត្រៃត្រឹង្សា។
ពង្សពុទ្ធវិសុទ្ធសោភា មើលយល់ខាន់ថ្លា គិតថាជាកាំបិតស្នៀត។
ហត្ថាស្រវាចាប់សៀត ពុំទាំងនឹកឆ្ងៀត ថាជាតិរបស់ថោកថ្លៃ។
នឹងថ្លែងឯដំរីជ័យ ដើរមកដល់នៃ មុខរោងពង្សពោធិញ្ញាណ។
ដាក់អង្គជួញជង្ឃប្រុងប្រាណ ទ្រោមទ្រុឌលុតបាន ក្រួញក្រាបរាបបន្ទាបកាយ។
រីឯពោធីឆោមឆាយ យល់ដំរីថ្វាយ បង្គំប្រណម្យថ្នោះណា។
អ្នកគិតស្មានថាគជសារ ជួលដោយយាត្រា ជំពប់ជង្គត់ឈើព្រៃ
អ្នកចេញពីរោងឆាប់ខ្មី មើលដំរីជ័យ នឹកម្តងថាសាចាប់ហើយ។



ស្រែកថាឱលោកអ្នកអើយ ដំរីជួលហើយ ថ្វីឡើយមិនមកជួយវា។
រាស្ត្រពលសាកលយោធា ស្តាប់ស័ព្ទវាចា វន្ទាទូលតបឆ្លាសឆ្លើយ។
រីដំរីនេះម្ចាស់អើយ ដោយយើងមើលហើយ មិនមែនជាជួលឡើយណា។

ដំរីនេះវាវន្ទា ខ្លាចបុណ្យសម្ភារ នៃលោកអ្នកមានបារមី។
ពង្សពុទ្ធវិសុទ្ធពិសី សួរគេវិញខ្មី ថាហៃបងប្អូនរាល់គ្នា។
លោកអ្នកមានបុណ្យសម្ភារ លោកនៅត្រង់ណា មេត្តាប្រាយប្រាប់ខ្ញុំផង។
ឱ្យខ្ញុំបានឃើញជាម្តង បំណាច់បំណង មោះមកពីនាយដល់អាយ។
សេនាយោធាទាំងឡាយ ក្រួញក្រាបថ្វាត់ថ្វាយ បង្គំប្រណម្យទូលថា។
បពិត្រអម្ចាស់ថ្លៃថ្លា មិនមានអ្នកឯណា ក្រៅពីព្រះអង្គឡើយហោង។
ព្រះពោធិសត្តឆ្លើយស្នង ថាហ៏! អ្នកបង កុំឡូកកុំឡឹយច្នេះណា។
ខ្លួនខ្ញុំនេះឬក្សត្រា មានបារមីតា កុំអ្នកមកថាជាល្បែង។
សួររកអ្នកមានបុណ្យព្រេង មកប្រាប់បង្វែង ចំអកឡកលយឱ្យគ្នា។



សម្រង់ចាករឿងល្បែង ចៅស្រទបចេក
ដោយបណ្ឌិត យស ឱន (ឆ្នាំ១៨៨៩)